អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ៤ ចេញផ្សាយ ខែមេសា ឆ្នាំ២០២២

## ប្រភេទសវនកម្មផ្ទៃក្នុង




ដោយអនុលោមតាមអនុក្រឹត្យលេខ១១៣ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល៥ ឆ្នាំ (២០២១-២០២៥) អង្គភាពសវនកម្មផ្ទៃក្នុងនៃ **អ.ស.ហ.** បានកំណត់នូវប្រភេទសវនកម្មដូចជា៖ សវនកម្មអនុលោមភាព សវនកម្មប្រតិបត្តិការនិងផែនការសកម្មភាព សវនកម្មហិរញ្ញវត្ថុ សវនកម្មសមិទ្ធកម្ម សវនកម្មធនធានមនុស្ស សវនកម្មលើទ្រព្យសកម្ម និងសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ។

ដោយឡែក អនុលោមតាមសៀវភៅណែនាំសវនកម្មផ្ទៃក្នុងរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រភេទនៃសវនកម្មត្រូវបានកំណត់ដូចខាងក្រោម៖

**-សវនកម្មលើប្រតិបត្តិការ៖** សំដៅលើការពិនិត្យលើការប្រើប្រាស់ធនធានរបស់អង្គភាពដើម្បីវាយតម្លៃថាតើធនធានទាំងនោះត្រូវបានប្រើប្រាស់ដោយប្រសិទ្ធភាព និងប្រសិទ្ធផលឬទេ ដើម្បីសម្រេចគោលបំណង និងបេសកកម្មរបស់សវនដ្ឋាន។ សវនកម្មនេះមានបញ្ចូលនូវធាតុនៃប្រភេទសវនកម្មផ្សេងៗទៀត។

**-សវនកម្មហិរញ្ញវត្ថុ៖** ការពិនិត្យលើកិច្ចបញ្ជិកាគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការធានាអះអាង ការអនុញ្ញាត និងកិច្ចការសក្ខីបត្រ និងការទូទាត់ថវិកា។ គោលបំណងនៃសវនកម្មប្រភេទនេះ គឺផ្ទៀងផ្ទាត់ថាមានយន្តការត្រួតពិនិត្យគ្រប់គ្រាន់ចំពោះសាច់ប្រាក់ និងទ្រព្យប្រហាក់ប្រហែលដទៃទៀត តើមានយន្តការគ្រប់គ្រងគ្រប់គ្រាន់ទេលើការទិញ និងការប្រើប្រាស់ធនធាន។ មិនដូចសវនកម្មហិរញ្ញវត្ថុផ្ទៃក្រៅទេ សវនកម្មហិរញ្ញវត្ថុផ្ទៃក្នុងមិនបញ្ចេញមតិជំនាញលើភាពត្រឹមត្រូវលើរបាយការណ៍ហិរញ្ញវត្ថុឡើយ។

**-សវនកម្មលើភាពអនុលោម៖** ការបញ្ជាក់លើការអនុលោមទៅតាមច្បាប់បទប្បញ្ញត្តិ គោលនយោបាយ នីតិវិធី។ ឧទាហរណ៍៖ ច្បាប់ អនុក្រឹត្យ ប្រកាស សារាចរណែនាំ និងគោលការណ៍ផ្សេងៗរបស់ក្រសួង និងការកំណត់នៃស្ថាប័នច្បាប់ផ្សេងៗ។ អនុសាសន៍ច្រើនផ្តល់ឱ្យមានការកែលម្អក្នុងដំណើរការ និងយន្តការគ្រប់គ្រងក្នុងបំណងធានាឱ្យមានការគោរពបទដ្ឋានច្បាប់។

**-ការត្រួតពិនិត្យការគ្រប់គ្រងផ្ទៃក្នុង៖** ផ្តោតលើសមាសធាតុនៃសកម្មភាពសំខាន់ៗរបស់សវនដ្ឋាន ដូចជា ប្រាក់បៀវត្សលាភការ ការងារសាច់ប្រាក់ សារពើភណ្ឌ និងសម្ភារៈឧបករណ៍ និងការរក្សាសុវត្ថិភាព អំណោយ និងកិច្ចព្រមព្រៀង និងរបាយការណ៍ហិរញ្ញវត្ថុសុទ្ធតែជាកម្មវត្ថុនៃការពិនិត្យនេះ។

**-សវនកម្មលើការបន្លំ៖** សំដៅលើការអនុវត្តសកម្មភាពសវនកម្មពិសេស នៅកន្លែងដែលការបន្លំកើតមានឡើង ឬត្រូវបានសង្ស័យ ដើម្បីជួយឱ្យប្រធានសវនកម្មអាចរកឃើញ ឬច្បាស់ថាមាន និងទំហំនៃការបន្លំ ហើយផ្តល់នូវភស្តុតាងចាំបាច់សម្រាប់ដំណោះស្រាយតាមផ្លូវច្បាប់។



ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

អង្គភាពសវនកម្មផ្ទៃក្នុង

# អត្ថបទប្រចាំខែ

លេខ ៤ ចេញផ្សាយ ខែមេសា ឆ្នាំ២០២២

**-សវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន÷** ការពិនិត្យលើបរិស្ថានគ្រប់គ្រងផ្ទៃក្នុងនៃប្រព័ន្ធដំណើរការព័ត៌មានស្វ័យប្រវត្តិ និងបញ្ជាក់ថាតើមន្ត្រីប្រើប្រាស់ប្រព័ន្ធយ៉ាងដូចម្ដេច។ សវនកម្មនេះជាទូទៅវាយតម្លៃប្រព័ន្ធធាតុចូល ធាតុចេញ យន្តការត្រួត-ពិនិត្យដំណើរការ ផែនការចម្លងទុកនិងការស្តារឡើងវិញប្រព័ន្ធសន្តិសុខ និងប្រព័ន្ធកុំព្យូទ័រ។ ការងារសវនកម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន អាចផ្តោតលើប្រព័ន្ធបច្ចុប្បន្ន និងប្រព័ន្ធស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍។ បទពិសោធន៍សំខាន់ គឺការបញ្ចូលគ្នារវាងសវន-កម្មលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាមួយសវនកម្មប្រភេទផ្សេងទៀត ជាពិសេសកន្លែងដែលមានកម្រិតស្វ័យប្រវត្តិកម្មខ្ពស់។

**-សវនកម្មសមិទ្ធកម្ម÷** សំដៅលើការពិនិត្យលើកម្មវិធី មុខងារប្រតិបត្តិការ ឬប្រព័ន្ធគ្រប់គ្រងនិងនីតិវិធីនៃនាយកដ្ឋាន/អង្គភាព/ការិយាល័យ ដើម្បីវាយតម្លៃថាតើសវនដ្ឋានអាចសម្រេចបានភាពសន្សំសំចៃ ប្រសិទ្ធភាព ប្រសិទ្ធផល នៅក្នុងការប្រើប្រាស់ធនធានដែលមានយ៉ាងណា។ ការពិនិត្យ គឺសត្យានុម័ត និងជាប្រព័ន្ធដែលជាទូទៅបានប្រើវិធីសាស្ត្រជំនាញ និងលម្អិតដល់កម្រិតរចនាសម្ព័ន្ធ។

***អត្ថបទ÷** លោក **ទឿន គុយអេង***

***ឯកសារយោង÷***

*-អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទអាជ្ញា-ធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ*

*-ផែនការអភិវឌ្ឍន៍អង្គភាពសវនកម្មផ្ទៃក្នុងនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់រយៈពេល៥ឆ្នាំ (២០២១-២០២៥)*

*-សៀវភៅណែនាំសវនកម្មផ្ទៃក្នុងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

អត្ថបទអប់រំខ្លីៗស្តីពីសវនកម្មត្រូវបានរៀបរៀងដោយមន្ត្រីរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ.
ទស្សនៈដែលមាននៅក្នុងអត្ថបទនេះ មិនមែនជាទស្សនៈរបស់អង្គភាពសវនកម្មផ្ទៃក្នុងនៃ អ.ស.ហ. ទេ ប៉ុន្តែជាទស្សនៈរបស់អ្នករៀបរៀងផ្ទាល់ខ្លួន ឬរបស់ក្រុមការងារ។

ស្កេនទាញយកអត្ថបទស្តីពីសវនកម្មផ្សេងទៀត